# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚

## កិច្ចព្រមព្រៀង

ស្តីពីការបន្តព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និងក្រុមហ៊ុន ម៉េម៉័រអង្គរ (ខេមបូឌា), សាខា សណ្ឋាគារម៉េម៉័រសៀមរាប កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ០០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន ម៉េម៉័អង្គរ (ខេមបូឌា), សាខា សណ្ឋាគារម៉េម៉័រសៀមរាប មានអាសយដ្ឋានស្ថិតនៅ ភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

### សមាសភាពចូលរួមក្នុងអង្គប្រជុំមាន៖

| **ក. តំណាងភាគីនិយោជក** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក វឿន ពិនិត្យ | នាយកគ្រប់គ្រងទូទៅ | ០៦៩ ៣១៨ ៧៧៧ |
| កញ្ញា អាន មុន្នី | ហិរញ្ញវត្ថុ | ០៦៩ ៤៨៥ ៥៣១ |

| **ខ. តំណាងភាគីកម្មករនិយោជិត** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក ឆេង ឆង | ប្រតិភូបុគ្គលិកពេញសិទ្ធ | ០៦៩ ៤៧៥ ៧៧៧ |
| កញ្ញា ស៊ុន សុខន | ប្រតិភូបុគ្គលិកជំនួយ | ០៧៨ ៩៨៥ ២១៩ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធទៅនឹង ការព្យួរកិច្ចសន្យាការងារឲ្យបានសមស្របតាម សេចក្តីណែនាំលេខ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីទាំងពីរបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតចំនួន៥០នាក់ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០២២ ដោយទទួលបាននូវប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លាអា-មេរិក ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺ COVID-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូលហើយបង្ខំចិត្តផ្អាកអាជីវកម្មមួយរយៈ។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១១ និង ៣០នាទី ព្រឹក ថ្ងៃ ខែ ឆ្នាំដដែល ដោយមានការចុះហត្ថលេខា ព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម៖

**តំណាងភាគីនិយោជក**

ហត្ថលេខា/ស្នាមមេដៃ

លោក រឿន ពិនិត្យ

នាយកគ្រប់គ្រងទូទៅ

កញ្ញ អាន មុន្នី

ហិរញ្ញវត្ថុ

**តំណាងភាគីកម្មករនិយោជិត**

ហត្ថលេខា/ស្នាមមេដៃ

លោក ឆេង ឆង

ប្រតិភូបុគ្គលិកពេញសិទ្ធិ

កញ្ញា ស៊ុន សុខន

ប្រតិភូបុគ្គលិកជំនួយ